ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

<u>នាយកដ្ឋានព័ត៌មាន</u>

នៅព្រឹកថ្ងៃទី **១៩** ខែ **មករា** ឆ្នាំ២០១៩ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបឯកឧត្តម **Scott Ryan ប្រធានព្រឹទ្ធសភាអូស្ត្រាលី** នៅទីស្តីការក្រសួង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះទស្សនកិច្ចរបស់ឯកឧត្តម **Scott Ryan** មកកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំ**វេទិកាសភាអាស៊ីប៉ាស៊ីហ្វិកលើកទី ២៧** នៅខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានថ្លែងអំណរគុណដល់ប្រទេសអូស្ត្រាលី ដែលបានជួយរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនឯកឧត្តម **Scott Ryan** ជ្រាបអំពីស្ថានការណ៍ជាក់ស្តែងនៅកម្ពុជា រួមមានលទ្ធផលនៃការបោះឆ្នោតសកលកាលពីឆ្នាំ២០១៨ ដែលប្រព្រឹត្តទៅដោយស្ងៀមស្ងាត់ គ្មានអំពើហិង្សា សេរី និងតម្លាភាព និងវិធានការណ៍នានារបស់រាជរដ្ឋាភិបាលក្រោយពីការបោះឆ្នោត ដើម្បីលើកកំពស់ការឯកភាពជាតិ និងកែលម្អរស្ថានភាពនយោបាយ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានបញ្ជាក់អំពីតួនាទីឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ ក្នុងការងារតាក់តែងច្បាប់ការងារ អភិបាលកិច្ច និងការដោះបញ្ហាសង្គម។

ឯកឧត្តមប្រធានព្រឹទ្ធសភា បានថ្លែងអំណរគុណឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលបានទទួលជួប និងបានថ្លែងកោតសរសើរចំពោះការរៀបចំវេទិកាអាស៊ីប៉ាស៊ីហ្វិក (**APPS**) លើកទី ២៧ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ មានការផ្លាស់ប្តូរយោបល់យ៉ាងផុលផុស ស្តីពីបញ្ហាប្រឈមទាំងឡាយក្នុងពិភពលោក។

ស្តីពីទំនាក់ទំនងកម្ពុជា-អូស្ត្រាលី ឯកឧត្តម **Scott Ryan** បានសម្តែងសេចក្តីរីករាយ ដោយបានសង្កេតឃើញថា ការជួយគាំទ្ររបស់អូស្ត្រាលីដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា បានរួមចំណែកធ្វើឲ្យកម្ពុជាមានការរីកចម្រើនដូចឃើញសព្វថ្ងៃ ហើយតាមរយៈកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ ក៏ដូចជាលំហូរទេសចរអូស្ត្រាលីមកទស្សនាកម្ពុជា បានជួយបង្កើនការប្រាស្រ័យទាក់ទង និងផ្លាស់ប្តូរវប្បធម៌រវាងប្រជាជនទាំងពីរ។ ឯកឧត្តម **Scott Ryan** បានបញ្ជាក់ថា អូស្ត្រាលីនឹងបន្តជម្រុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានមានប្រសាសន៍ផងដែរថា រាជរដ្ឋាភិបាលកម្ពុជា បាននិងខិតខំអស់ពីលទ្ធភាព ដើម្បីលើកកំពស់សិទ្ធិមនុស្ស និងជម្រុញដំណើរការលិទ្ធិប្រជាធិបតេយ្យ ប៉ុន្តែនឹងមិនយកឯករាជ្យភាព អធិបតេយ្យភាព របស់ខ្លួនទៅប្តូរនឹងជំនួយទេ។

កិច្ចពិភាក្សា បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃ សៅរ៍ ១៤ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៩